**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២០០៤ ព.ណ.ស.ជពកព

ថ្ងៃច័ន្ទ ៨កើត ខែជេស្ឋ ឆ្នាំមមីអដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំវេទិកាពាណិជ្ជកម្មឌីជីថលកម្ពុជា និងពិព័រណ៍អនឡាញ លើកទី៣
(The 3rd Cambodia Digital Trade Forum and Online Expo)

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជំណឹងដល់ **លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន ម្ចាស់ក្រុមហ៊ុន និងសាធារណជនទាំងអស់** ជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងរៀបចំ **«វេទិកាពាណិជ្ជកម្មឌីជីថលកម្ពុជា និងពិព័រណ៍អនឡាញ លើកទី៣ (The 3rd Cambodia Digital Trade Forum and Online Expo)»** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១-១៣ ខែកញ្ញា ឆ្នាំ២០២៦ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ (អគារ G-L) រាជធានីភ្នំពេញ ក្នុងគោលបំណងជំរុញកិច្ចពិភាក្សាអំពីទិដ្ឋភាពពាណិជ្ជកម្មឌីជីថល ក្របខ័ណ្ឌគោលនយោបាយ ការផ្សព្វផ្សាយ និងជំរុញការនាំចេញផលិតផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការជំរុញការប្រើប្រាស់ថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុក និងអន្តរជាតិ ជាពិសេសថ្នាល CambodiaTrade.com របស់ក្រសួងពាណិជ្ជកម្ម។ ជាមួយគ្នានេះ **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងផ្តល់កិត្តិយសអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធវេទិកាខាងលើជាផ្លូវការនារសៀលថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៦ ផងដែរ។

ព្រឹត្តិការណ៍ខាងលើនឹងមានៈ ១-ការថ្លែងសុន្ទរកថាគន្លឹះ ព្រមទាំងកិច្ចសន្ទនាកម្រិតថ្នាក់ដឹកនាំ ការបង្ហាញប្រព័ន្ធអេកូឡូស៊ីរបស់ក្រុមហ៊ុន Apple និងបញ្ញាសិប្បនិម្មិត (AI) សន្តិសុខសាយប័រនិងទំនុកចិត្តឌីជីថល ភស្តុភារកម្មឆ្លងកាត់ព្រំដែន, ២-វេទិកាស្ត្រីក្នុងវិស័យពាណិជ្ជកម្មឌីជីថល, ៣-កម្មវិធីបង្កើនសមត្ថភាពនិងភាពអង់អាចរបស់យុវជនតាមរយៈការជជែកដេញដោល និងកម្មវិធីប្រកួតប្រជែងជាក្រុម (Hackathon), និង៤-ការរៀបចំស្តង់តាំងបង្ហាញផលិតផល និងសេវាកម្មឌីជីថលជាច្រើនប្រភេទរួមមានៈ ផលិតផលកម្ពុជា #MadeInCambodia ផលិតផលស្ត្រី #MadeByHer ផលិតផលសម្គាល់ភូមិសាស្ត្រ ផលិតផលម៉ាកសមូហភាព អាហារនិងភេសជ្ជៈ សេវាកម្មអ៊ីនធឺណែតពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ធនាគារ ភ្នាក់ងារដឹកជញ្ជូន សេវាកម្មក្លោដ និង AI ជាដើម។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម **សូមអញ្ជើញ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន ម្ចាស់ក្រុមហ៊ុន និងសាធារណជន** ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផល និងសេវាកម្មក្នុងព្រឹត្តិការណ៍ខាងលើ សូមអញ្ជើញបំពេញបែបបទស្នើសុំចូលរួមតាមរយៈ QR Code ខាងក្រោម **ឱ្យបានមុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦** ជាកំណត់។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្មលេខ ១២៦៦ ឬតាមរយៈអ៊ីម៉ែលៈchao.katphouy@moc.gov.kh។

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 2004 .MOC...D/.TPEA

Phnom Penh, 8 June 2026

# ANNOUNCEMENT ON THE 3rd CAMBODIA DIGITAL TRADE FORUM AND ONLINE EXPO

The Ministry of Commerce has the honor to inform all traders, manufacturers, investors, business owners, and the public that the Ministry of Commerce will organize **"The 3rd Cambodia Digital Trade Forum and Online Expo"** from 11 to 13 September 2026, at the Koh Pich Convention and Exhibition Center (Buildings G-L), Phnom Penh. The event aims to promote discussions on digital trade landscapes, policy frameworks, and the promotion and acceleration of Cambodian products exports to international markets. This will be achieved by encouraging the utilization of both domestic and international e-commerce platforms, particularly the Ministry of Commerce's CambodiaTrade.com. Furthermore, **Her Excellency CHAM Nimul**, Minister of Commerce, will preside over the official opening ceremony on the afternoon of 11 September 2026.

The event will feature: 1-Keynote speeches and high-level leadership dialogues focusing on the Apple Ecosystem and Artificial Intelligence (AI), Cybersecurity and Digital Trust, and Cross-border Logistics, 2-Women in Digital Trade Forum, 3-Youth Empowerment initiatives through Digital Trade Debate and Hackathon Competition and 4-Exhibition showcasing various types of digital products and services, including: Cambodian products #MadeInCambodia, products made by women #MadeByHer, Geographical Indication (GI) products, Collective Marks products, food and beverages, internet services, e-commerce, banking, logistics/delivery agencies, as well as cloud and AI services.

In this regard, the Ministry of Commerce cordially invites all traders, manufacturers, investors, business owners, and the public who wish to participate and showcase products and services at this event to register via the QR Code provided below no later than **25 August 2026**. For further information, please contact the MOC Call Center: 1266 or via email at chao.katphouy@moc.gov.kh.

GO.gov.KH

THANK YOU!

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469